# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

NTFP
NON-TIMBER FOREST PRODUCTS ORGANIZATION
PRESERVING NATURAL RESOURCES
EMPOWERING COMMUNITIES







# របាយការណ៍
# សង្ខេបប្រចាំ
# ឆ្នាំ ២០២០




ទូរស័ព្ទលេខ: ០៧៥ ៩៧៤ ០៣៩

ប្រអប់សំបុត្រលេខ: ៨៩០០៩

អ៊ីម៉ែល: edntfp@ntfp-cambodia.org

edntfp.cambodia@gmail.com

famntfp@ntfp-cambodia.org

អាសយដ្ឋាន:ភូមិអូរកន្ទិល,សង្កាត់បឹងកន្សែង,ក្រុងបានលុង,ខេត្តរតនគិរី

# មាតិកា


I. **គុណតម្លៃនិងគោលការណ៍** ........ ១

II. **របាយការសង្ខេបតាមកម្មវិធីនិងសមិទ្ធិផលសម្រេចបាន** ........ ២

២.១.កម្មវិធីគ្រប់គ្រងធនធានធម្មជាតិ(NRM) ........ ២

២.១.១ គំរោង IC-LEDAPសហគមន៍ជនជាតិដើមភាគតិច ដឹកនាំតស៊ូមតិ ........ ២

២.១.២ គំរោងធ្វើឲ្យប្រសើឡើងនូវសេវាអប់រំ និងការចិញ្ចឹមជីវិតសហគមន៍(PLE)........ ៣

២.១.៣ ការពង្រឹងនិងគាំពារសិទ្ធិដីធ្លីជាប្រពៃណីរបស់ជនជាតិដើមភាគតិច (SPIRIT)........ ៣

២.១.៤ គម្រោងការលើកកំពស់ជីវភាពសហគមន៍តាមរយៈការអប់រំយុវអង្វែង........ ៤

២.២.កម្មវិធីលើកស្ទួយ និងពង្រឹងសហគមន៍ (CEA) ........ ៧

២.២.១.លទ្ធផលសម្រេចបានពីគម្រោងការលើកកំពស់សិទ្ធិសហគមន៍ខេត្តព្រះវិហារ ........ ៧

២.២.២.លទ្ធផលសំខាន់ៗរបស់គម្រោង"ជុំនាន់ថ្មី" (New Generation) ........ ៩

២.២.៣.លទ្ធផលគម្រោង"បញ្ឈប់អាពាហ៍ពិពាហ៍លើកុមារ" ........ ១៥

២.៣.កម្មវិធីអភិវឌ្ឍសហគមន៍និងការអប់រំ (CDE)........ ១៩

២.៣.១.លទ្ធផលសំខាន់ៗ របស់គម្រោងអក្ខរកម្មអប់រំពីរភាសាក្នុងខេត្តរតនគីរី ........ ១៩

III. **របាយការណ៍សង្ខេបហិរញ្ញវត្ថុ**........ ២០

IV. **សមាជិកក្រុមប្រឹក្សាភិបាលរបស់អង្គការ**NTFP ........ ២៣

# I. គុណតំលៃនឹងគោលការណ៍

## គុណតំលៃ

- គោរពលើកកំពស់វប្បធម៌និងប្រពៃណីជនជាតិដើមភាគតិច
- ស្ត្រីជាចលករួមចំណែកក្នុងការផ្លាស់ប្តូរសង្គម
- ធ្វើការជាក្រុមយ៉ាងសកម្មនិងស្វាហាប់
- គណនេយ្យភាពនិងតម្លាភាព

## គោលការណ៍

- ធ្វើការតាមរយៈរចនាសម្ព័ន្ធដឹកនាំបែបប្រពៃណីដែលមានលក្ខណៈបទដ្ឋានគុណភាព និង បរិមាណសម្រាប់ការចូលរួមរបស់ស្ត្រីនៅគ្រប់សកម្មភាពនិងក្នុងជួរគណៈកម្មការ ទាំងអស់។
- ផ្តោតសំខាន់លើវិធីសាស្ត្របែបចូលរួមដែលសហគមន៍អាចជ្រើសរើសការអភិវឌ្ឍន៍ សមស្របតាមតម្រូវការរបស់ពួកគេ។
- គាំទ្រសមាជិកសហគមន៍ដើម្បីអោយពួកគេអាចនិយាយនិងលើកឡើងពីសិទ្ធិរបស់ ពួកគេ។
- គាំទ្រការប្រើប្រាស់ភាសាមូលដ្ឋាននិងលើកទឹកចិត្តបុគ្គលិកជនជាតិដើមភាគតិច។
- បញ្ជ្រាបយេនឌ័រគ្រប់ផ្នែកនិងគ្រប់ដំណាក់កាលទាំងអស់នៃវដ្តគម្រោង។
- ភាពជាដៃគូរជាមួយទីភ្នាក់ងាររដ្ឋាភិបាលនិងសង្គមស៊ីវិល។
- មិនរើសអើងជាតិសាសន៍ក្នុងការជ្រើសរើសបុគ្គលិក។
- រាល់ការធ្វើសេចក្តីសម្រេចចិត្តគឺអនុលោមយកគោលការណ៍ប្រជាធិបតេយ្យក្នុងការ លើកកំពស់សិទ្ធិបញ្ចេញមតិរបស់បុគ្គលិកនិងអ្នកដទៃ។

## II. របាយការសង្ខេបតាមកម្មវិធីនិងសមិទ្ធផលសម្រេចបាន

### ២.១.កម្មវិធីគ្រប់គ្រងធនធានធម្មជាតិ(NRM)

### ២.១.១ ៖ គំរោង IC-LEDAPសហគមន៍ជនជាតិដើមភាគតិច ដឹកនាំតស៊ូមតិ

- ក្រុមអ្នកដឹកនាំសហគមន៍CAB,LEC,Youth 23នាក់ ដែលបានទទួលការកសាងសមត្ថភាពពីគំរោង គេបានទៅពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងធនធានធម្មជាតិ នៅតាមសហគមន៍។ ដោយបង្កើតក្រុម យុវជន និងក្រុមស្ត្រីនៅតាមភូមិហើយពួកគេបានទទួលការអប់រំផ្សព្វផ្សាយអំពីតួនាទីចូលរួមគ្រប់គ្រងធនធានធម្មជាតិ។យុវជន និងក្រុមស្ត្រីកំពុងដំណើរការចូលរួមផែនការត្រួតពិនិត្យព្រៃជាមួយក្រុម CAB,LEC, Youth ខាងលើ ក្នុងខែវិច្ឆិកា ឆ្នំ ២០២០កន្លងទៅនេះ។
- ក្រុមអ្នកដឹកនាំសហគមន៍CAB,LEC,Youth 23 នាក់បានប្រជុំជាមួយអាជ្ញាធរឃុំពិនិត្យ ដោះស្រាយករ ណីទី១ប្រជាពលរដ្ឋក្នុងសហគមន៍កាប់ព្រៃ ក្នុងសហគមន៍ព្រៃឈើ
យកដីធ្វើចំការកម្មសិទ្ធ។ពិនិត្យដោះស្រាយករណីទី២ប្រជាពលរដ្ឋ២គ្រួសារមកពីក្រៅ សហគមន៍(មិនមែនសមាជិកសហគមន៍ព្រៃឈើ)កាប់ព្រៃក្នុងសហគមន៍ ព្រៃឈើយកដីធ្វើចំការកម្មសិទ្ធ។ពិនិត្យដោះស្រាយករណីទី៣ ព្រំប្រទល់ដីសម្ងហភាពភូមិកងកុយជាន់គ្នាជាមួយព្រំដីសហគមន៍ព្រៃឈើ។
- សហគមននីតិបុគ្គលចំនួន ៤២ភូមិបានពិនិត្យតួនាទីឡើងវិញដោយ សិក្ខាសាលាពិគ្រោះយោបល់ជាមួយអាជ្ញាធរថ្នាក់ឃុំ។ ភាពអសកម្មក្នុងការបំពេញតួនាទីរបស់គណកម្មការសហគមននីតិបុគ្គលនាំអោយមានបទល្មើសលើដីសម្ងហភាព នេះជាការរកឃើញក្នុងសិក្ខាសាលាថ្ងៃ១៧វិច្ឆិកា២០២០ ។ ក្នុងភូមិនិមួយៗបានជ្រើសរើសសកម្មជន ចំនួន៣នាក់ក្នុងជួគណកម្មការនីតិបុគ្គលជាតំណាងបណ្តាញសហគមន៍នីតិបុគ្គលទំនាក់ទំនងជាមួយអាជ្ញាធរនិងអង្គការសង្គមសីវិលថ្នាកខេត្ត និងថ្នាក់ជាតិ។ តំណាងបណ្តាញនេះធ្វើការជិតស្និទជាមួយ CAB,LEC,Youth 23 នាក់ជំវិញបញ្ហាទំនាស់ដីធ្លី។

## ២.១.២ ៖ គំរោងធ្វើឲ្យប្រសើឡើងនូវសេវាអប់រំ និងការចិញ្ចឹមជីវិតសហគមន៍(PLE)

គំរោងនេះមានភូមិគោលដៅខេត្តរតនគីរី ២១ភូមិ,៦ឃុំ,៣ស្រុក។ខេត្តស្ទឹងត្រែង ១៧ភូមិ, ៦ឃុំ,២ស្រុក។ ខេត្តព្រះវិហារ ១២ភូមិ, ៦ឃុំ, ២ស្រុក។

- កសិករចំនួន២៣គ្រួសារបានកើនឡើងនូវប្រាក់ចំណូលដែលបានពីការលក់ផលិតផលកសិកម្មរបស់ខ្លួនចន្លោះពី៥០០ដុល្លារដល់៩៣៨ដុល្លារក្នុងមួយឆ្នាំក្នុងមួយគ្រួសារ។ មានកសិករចំនួន២៧គ្រួសារទទួលប្រាក់ចំណូលដែលបានពីការលក់ផលិតផលកសិកម្មរបស់ខ្លួនតិចជាង៥០០ដុល្លារគឺចន្លោះ៣០០ទៅ៤៦៩ដុល្លារ ។ នៅបំណាច់ឆ្នាំ២០២០កន្លងទៅនេះកសិករ១៦៨គ្រួសារដែលមានសមាជិកសរុប៨៩០នាក់បានប្រសើឡើងនូវអាហាររូបបថមតាមរយ:បន្លែជាអាហារប្រចាំថ្ងៃ។
- ធនធានយុវជនក្នុងសហគន៍១០ភូមិចំនួន២០នាក់,ស្រី១៤នាក់បានរៀនជំនាញ Participant Action Research ហើយពួកគេបានប្រើជំនាញនេះជាមួយសហគមន៍ចំនួន៨ភូមិដោយបានលើកឡើងនូវតំរូវការជាអារទិភាព និងរៀបចំគំរោងចំនួន៦គំរោងសំណើរ ។សំណើទាំង៦គំរោងត្រូវបានគាំទ្រដោយNTFPតាមរយ:ថវិកា MAដើម្បីពួកយុវជនទាំនោះអនុវត្តគំរោងដោះស្រាយបញ្ហាដែលឆ្លើយតបតំរូវការក្នុងសហគមន៍ដូចជាជួសជុលផ្លូវដឹកជញ្ជូនកសិផល,ស្ពានសិស្សធ្វើដំណើរឆ្លងកាត់ទៅសាលារៀន,ចាក់វាក់សាំងសត្វពាហ:ន:,សង់បង្គន់អានាម័យសាលាភូមិ, សង់បណ្ណាល័យសហគមន៍, វិនិយោគក្លឹបយុវជនចិញ្ចឹមមាន់, ។
- ក្នុងចំណោម១០ភូមិនៅឆ្នាំ២០២០ក្លឹបកុមារចំនួន ៧ ដែលមានសិស្ស ៦៣ នាក់បានពង្រឹងតួនាទីទំនាក់ទំនង ជាមួយគណកម្មការទ្រទ្រង់សាលា។ក្នុងចំណោម១២សាលាបឋមសិក្សា មានសាលាចំនួន៩ មានការប្រជុំជាទៀងតាត់ប្រចាំត្រីមាសនិងមានវត្តមានច្រើនជាង៨០%ក្នុងការប្រជុំដោះស្រាយបញ្ហានិងតំរូវការអប់រំ។

## ២.១.៣ ៖ ការពង្រឹងនិងគាំពារសិទ្ធិដីធ្លីជាប្រពៃណីរបស់ជនជាតិដើមភាគតិច (SPIRIT)

- ➢ សហគមន៍ព្រៃឈើបីតំបន់ទំហំ៧៥៩១ហិចតា ដែលទទួលបានការទទួលស្គាល់ពីក្រសួងកសិកម្មក្នុងការធ្វើសហគមន៍ព្រៃឈើ និងបានចុះ កិច្ចព្រមព្រៀងអនុវត្តផែន

ការគ្រប់គ្រងជាមួយរដ្ឋបាលព្រៃឈើ ត្រូវបានអាជ្ញាធរអន្តរាគមន៍សហការជាមួយសហគមន៍ទប់ស្កាត់បទល្មើសការកាប់ទន្ទ្រានព្រៃយកដីជាកម្មសិទ្ធ។ ករណីកាប់ទន្ទ្រានយកដីក្នុងសហគមន៍ព្រៃឈើត្រូវបានរកឃើញចំនួន៥៦ករណី,២០៧គ្រួសារ និងផ្ទៃដីបានទន្ទ្រានប្រហែល២៥៩ហិកតា ។ដីជនជាតិដើមភាគតិចចំនួន៥ភូមិដែលបានចុះបញ្ជីនីតិបុគ្គលនិងបានប័ណ្ណកម្មសិទ្ធសមូហភាពត្រូវបានអាជ្ញាធរអន្តរាគមន៍ក្នុងការទប់ស្កាត់ការរំលោភបំពាន។

- សមាជិកសហគមន៍៤២៤នាក់ ស្រី១៥២នាក់ទទួលបានការផ្សព្វផ្សាយយល់ដឹងអំពីការគោរពអនុវត្តលក្ខន្តិកៈសហគមន៍ព្រៃឈើដីធ្លី។ គណកម្មការសហគមន៍២៥នាក់ ស្រី៧នាក់ទទួលបានការ កសាងសមត្ថភាពដឹកនាំគ្រប់គ្រងដីធ្លីព្រៃឈើ ។ គណកម្មការសហគមន៍១៥នាក់ទទួលបានជំនាញ GPS/Map/SMART Book និង ពួកគេបានដឹកនាំសមាជិកសហគមន៍៥០នាក់ចុះត្រួតពិនិត្យព្រៃដោយប្រើជំនាញ GPS/Map/SMART Book ធ្វើរបាយការណ៍ដើម្បី ដាក់ជូមអាជ្ញាធរដោះស្រាយ ។

## ២.១.៤ ៖ គម្រោងការលើកកំពស់ជីវភាពសហគមន៍តាមរយៈការអប់រំយុវអង្វែង

Output 1.1:

1.1.1: កសិករនៅក្នុងតំបន់គោលដៅដែលទទួលបានជំនាញបច្ចេកទេស ហើយយកទៅអនុវត្តន៍បានចំនួន(២០កសិករស្រី១៨នាក់ភូមិគោលដៅថ្មីមានភូមិឬស្សីស្រុកនិងភូមិទន្លាប់ឃុំរូសរាន់) ។(ភូមិគោលដៅចាស់មាន៤ភូមិ គឺភូមិបឹង ភូមិអូរ ឃុំរបៀប និងភូមិព្រាល ភូមិសន្លុងជ័យ ឃុំរក្សា មានចំនួនកសិករ ៥៥នាក់ ស្រី៣៥នាក់)។

1.1.2: ឆ្នាំ២០២០កសិករដែលបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសក្នុងតំបន់គោលដៅមានភូមិឬស្សីស្រុក និងភូមិទន្លាប់ មានចំនួន២៩នាក់ ស្រី ២៥នាក់ (កសិករបានរៀនគ្រប់មេរៀននិងពេញលេញ)។[1]កសិករគំរូចំនួន២នាក់ បានចែករំលែកចំណេះដឹង និងជំនាញពីការដាំបន្លែ ដល់សមាជិកកសិករក្នុងនិងក្រៅក្រុម (ក្នុងក្រុមមានចំនួន៧នាក់ និងក្រៅក្រុម ១៥នាក់)[2]។

Output 1.2:

1.2.1: កសិករនៅក្នុងតំបន់គោលដៅដែលទទួលបានជំនាញបច្ចេកទេស ហើយយកទៅអនុវត្តន៍បានចំនួន (២០កសិករ ស្រី១៨នាក់ភូមិគោលដៅថ្មីមានភូមិឬស្សីស្រុកនិងភូមិ

---

[1] យោងតាមបញ្ជីវត្តមានអ្នកចូលរួម រូបថតសកម្មភាព កំណត់ហេតុនៃវគ្គបណ្តុះបណ្តាល

2 កសិករឈ្មោះគង់ ផេត និងកសិករឈ្មោះ សៀន ផា រស់នៅភូមិទន្លាប់ ឃុំរូសរាន់ បានផ្ទេរចំណេះដឹង ជំនាញបច្ចេកទេសដាំបន្លែ ដល់សមាជិកក្នុងនិងក្រៅក្រុម

ទន្លាប់ ឃុំរួសរាន់) ។(ភូមិគោលដៅចាស់មាន៥ភូមិ គឺភូមិបឹង ភូមិអូរ ឃុំរបៀប និងភូមិព្រាល ភូមិសន្លុងជ័យ ឃុំរក្សា មានចំនួនកសិករ ៥៥នាក់ ស្រី៣៥នាក់)។

1.2.2: ឆ្នាំ២០២០





កសិករដែលបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសក្នុងតំបន់គោលដៅមានភូមិឬស្សីស្រុកនិងភូមិទន្លាប់មានចំនួន២៩នាក់ ស្រី ២៥នាក់ (កសិករបានរៀនគ្រប់មេរៀននិងពេញលេញ)។[3] កសិករគំរូចំនួន២នាក់ បានចែករំលែកចំណេះដឹងនិងជំនាញពីការដាំបន្លែ ដល់សមាជិកកសិករក្នុងនិងក្រៅក្រុម (ក្នុងក្រុមមានចំនួន៧នាក់ និងក្រៅក្រុម ១៥នាក់)[4]។

<u>Output 2.1:</u>

2.1.1: យុវជនដែលមានជំនាញ PAR មានចំនួន១២នាក់ ស្រី៦នាក់ (ភូមិគោលដៅថ្មី៤នាក់ ស្រី២នាក់ និងភូមិគោលដៅចាស់ មានចំនួន៨នាក់ ស្រី៤នាក់)។

2.1.2: យុវជន៨នាក់ ស្រី៤នាក់ ដែលបានអនុវត្តន៍ជំនាញPAR (យុវជនឆ្នាំ២០១៩ មាន៤នាក់ ស្រី២នាក់ និងយុវជន២០២០ មាន៤នាក់ ស្រី២នាក់)[5]។

<u>Output 3.1:</u>

3.1.1: ប្រជុំគណៈកម្មការទ្រទ្រង់សាលាមាន១៣ដង និងក្រុមប្រឹក្សាកុមារសរុបចំនួន ៩ដង ស្មើ៤សាលា ។ ឆ្នាំ២០១៩ មាន២សាលាគឺសាលាបឋមសិក្សាព្រាល និងសាលាបឋមសិក្សាអូរ និងឆ្នាំ២០២០មាន២សាលា គឺសាលាបឋមសិក្សាទន្លាប់ និងសាលាបឋមសិក្សាឬស្សីស្រុក)។

3.1.2: សាលាបឋមសិក្សាចំនួន៤បានប្រជុំគណកម្មការទ្រទ្រង់សាលា ដែលមានសមាជិកចូលរួម ១៩២នាក់ ស្រី ១០០នាក់ និងប្រជុំក្រុមប្រឹក្សាកុមារមានអ្នកចូលរួមចំនួន ១៥១នាក់ ស្រី៧៩នាក់[6]។

[3] យោងតាមបញ្ជីវត្តមានអ្នកចូលរួម រូបថតសកម្មភាព កំណត់ហេតុនៃវគ្គបណ្តុះបណ្តាល

[4] កសិករឈ្មោះគង់ រ៉េត និងកសិករឈ្មោះ សៀន ផា រស់នៅភូមិទន្លាប់ ឃុំរួសរាន់ បានផ្ទេរចំណេះដឹង ជំនាញបច្ចេទេសដាំបន្លែ ដល់សមាជិកក្នុងនិងក្រៅក្រុម

[5] តាមរយៈយុវជនភូមិបឹងបានចុះសួរសហគមន៍តាមផ្ទះ តាមការប្រជុំភូមិ រកឃើញបញ្ហាស្ពានខូច និងគៀងគរសហគមន៍ចូលជាបដិភាគ។ ភូមិសន្លុងជ័យ បានគៀងគរយុវជនបង្កើតជាក្លឹបយុវជនដឹកនាំយុវជនសំអាតភូមិ ចុះសួរសហគមន៍តាមផ្ទះក្នុងការគៀងគរដើម្បីដោះស្រាយបញ្ហាព្រែកប់ខ្មោច។ ភូមិទន្លាប់និងភូមិឬស្សីស្រុក បានចុះសិក្សាពីបញ្ហា និងតម្រូវការរបស់សហគមន៍។

[6] យោងតាមបញ្ជីវត្តមានអ្នកចូលរួម រូបថតសកម្មភាព កំណត់ហេតុប្រជុំ។ ចំនួនសមាជិកចូលរួម គឺបូកសរុប ត្រីមាសទី១ដល់ត្រីមាសទី៤។



▪ បានផ្ដល់សម្ភារៈ សាលាបឋមសិក្សាទន្លាប់ ទទួលបានបង្គន់អនាម័យ ចំនួន១ខ្នង មាន២បន្ទប់ សម្ភារៈធ្វើកញ្ចុះ ជួសជុលដំបូលសាលា តុ ក្ដាខៀនសរសេរហ្វីតចំនួន៤ សៀវភៅរឿងអមដោយរូបភាពចំនួន៦០ក្បាល បាល់ទាត់ចំនួន២ និងបាល់ទះចំនួន២។ ធ្វើបង្គន់អនាម័យ និងកញ្ចុះមានការចូលរួមជាបដិភាគពីសហាគមន៍ មានខ្សាច់ ថ្ម សសរ និងសាលា មានថ្លៃឈ្នួលជាង ។ សាលាបឋមសិក្សាឬស្សីស្រុក ទទួលបានសម្ភារៈដូចជា ធ្វើកន្លែងលាងដៃ ម៉ូទ័របូមទឹក ចំនួន១ ទូរដាក់សៀវភៅ ចំនួន១ ទ្វារឈើ ចំនួន២ បង្អួច ចំនួន២ ។ សាលាបឋមសិក្សាព្រាល ទទួលបានសម្ភារៈដូចជា ទោងរំអិលចំនួន១ ទោងយោលចំនួន១ ទូរដាក់សៀវភៅចំនួន១ បាល់ទាត់ ចំនួន២ ក្រដាសរាមពណ៌ចំនួន ៣ដុំ កន្ត្រៃឈ្មុតចំនួន១ឈុត និងកន្ត្រៃGiraff ចំនួន២។

សាលាបឋមសិក្សាអូរទទួលបានសម្ភារៈដូចជាជួលជុលសាលារៀនមួយខ្នង ដែលចូលរួម បដិភាគពីសហាគមន៍ មានខ្សាច់ ថ្ម កម្លាំងពលកម្ម និងសាលា មានឈើ។

3.1.11: ការគាំទ្រសួនបំណិនជីវិតក្នុងសាលា



ផ្ដល់សម្ភារៈធ្វើសួនបំណិនជីវិត និងផ្ដល់បច្ចេកទេសដល់សាលាបឋមសិក្សាចំនួន៣: ទន្លាប់ ភូមិអូរ ទទួលបាន និងសាលាព្រាលទទួលបានសម្ភារៈដូចជា៖ គ្រាប់ត្រកួនចំនួន៨កញ្ចប់, សំណាញ់ជ័រ២ដុំ,សណ្ដែកគួរចំនួន១កំប៉ុង,ត្រសក់ចំនួន១កំប៉ុង,ស្ពៃក្រញ៉ាញ់១កញ្ចប់ និងស្ពៃចង្កឹះចំនួន១កញ្ចប់។ បុគ្គលិកអង្គការNTFP បានផ្ដល់បច្ចេកទេស ពីការរៀបចំដី បណ្ដុះកូន លើករង តប្រព័ន្ធដំណក់ទឹក ទុយោសាច គ្របរង ដំឡើងសំណាញ់ទ្រើង ការថែទាំ និងការសម្អាត សួនមុននិងក្រោយប្រមូលផល។

*ការចែកអាល់កុល និងសាប៊ូ*



▪ អង្គការអនុផលព្រៃឈើបានសហការជាមួយអជ្ញាធរ ចែកអាល់កុលដល់សហគមន៍ព្រៃព្រ ក្រុមកសិករ និងយុវជន ក្នុងតំបន់គោលដៅចំនួន៦ភូមិ គឺភូមិព្រាល (សរុប៦៧គ្រួសារ) ទទួលបានអាល់កុលសរុបចំនួន១៣៤ដបនិងសាប៊ូសរុបចំនួន៦៧ដុំ។ភូមិសន្លុងជ័យ(សរុប៣៧គ្រួសារ) ទទួលបានអាល់កុលសរុបចំនួន៧៤ដប និងសាប៊ូសរុបចំនួន៣៧ដុំ។ភូមិអូរបឹង(សរុប៣៤គ្រួសារ)ទទួលបានអាកុលសរុបចំនួន៦៨ដបនិងសាប៊ូសរុបចំនួន៣៤ដុំ។ភូមិទន្លាប់(សរុប៤៥គ្រួសារ)ទទួលបានអាកុលសរុបចំនួន៩០ដបនិងសាប៊ូ៤៥ដុំ។ ភូមិឬស្សីស្រុក(សរុប៤០គ្រួសារ)ទទួលបានអាកុលសរុបចំនួន៨០ដបនិងសាប៊ូសរុបចំនួន៤០ដុំ[7]។ ចែកដល់សាលារៀនចំនួន៤និងសាលាឃុំចំនួន៣ក្នុងតំបន់គោលដៅទទួលបានអាល់កុល ៥លីត្រក្នុងមួយសាលារៀននិងសាលាឃុំ ។

## ២.២.កម្មវិធីលើកស្ទួយ និងពង្រឹងសហគមន៍ (CEA)

## ២.២.១ លទ្ធផលសម្រេចបានពីគម្រោងការលើកកំពស់សិទ្ធិសហគមន៍ខេត្តព្រះវិហារ

<u>Output 1.1:</u>



▪ អជ្ញាធរ ចំនួន ២៥ នាក់ ស្រី ចំនួន ២ នាក់ (មេភូមិ ក្រុមប្រឹក្សាឃុំ) ទទួលបានវគ្គបណ្តុះបណ្តាលពីការវាយតំលៃពីផលប៉ះពាល់បរិស្ថានដែលសម្របសម្រួលដោយមន្ទីរបរិស្ថាន មានរយៈពេល ២ ថ្ងៃ។ លទ្ធផលមុននិងក្រោយវគ្គបណ្តុះបណ្តាល: មុនវគ្គល្អមាន ២៨ % មធ្យម ២៨ % និងខ្សោយ ៤៤ % នៃអ្នកចូលរួម។ ក្រោយវគ្គ ល្អ ៤០ % មធ្យម ៣៦ % និងខ្សោយ ២៤ %។



▪ ជនបង្គោលចំនួន ២៥ នាក់ ស្រីចំនួន ២១ នាក់ ទទួលបានវគ្គ បណ្តុះបណ្តាលពីជំនាញសម្របសម្រួល ទាំនាក់ទំនងច្បាប់ភូមិ បាល និងគោលការណ៍ (FPIC) បានសម្របសម្រួលដោយបុគ្គលិក មានរយៈពេល ៣ ថ្ងៃ។ លទ្ធផលមុននិងក្រោយវគ្គបណ្តុះបណ្តាល: មុនវគ្គល្អមាន ០ % មធ្យម ៤៧ % និងខ្សោយ ៥៣ % នៃអ្នកចូលរួម។ ក្រោយវគ្គ ល្អ ៧៨ % មធ្យម ១៨ % និងខ្សោយ ៤ %។

[7] ក្នុងមួយគ្រួសារទទួលបានអាល់កុលចំនួន២ដប និងសាប៊ូចំនួន១ដុំ



▪ ជនបង្គោលចំនួន១១នាក់ និងសហគមន៍ចំនួន ៧នាក់ (សរុប ១៨នាក់ ស្រីចំនួន ៤ នាក់) ទទួលបានវគ្គបណ្តុះបណ្តាលពីរបៀបប្រើឧបករណ៍វាស់ជាតិពុលក្នុងទឹក (PHs) សម្របសម្រួលដោយមន្ត្រីកសិកម្មស្រុក មានរយៈពេល ២ ថ្ងៃ។ តាមការអង្កេតពេលរៀន និងអនុវត្តឃើញថា៧០ % នៃអ្នកចូលរួមមានការយល់ដឹងបានល្អ។

▪បុគ្គលិកចំនួន ៧ នាក់ស្រី ចំនួន ៥ នាក់ទទួល បានវគ្គបណ្តុះ បណ្តាលពីរបៀបប្រើឧបករណ៍វាស់ជាតិពុលក្នុងទឹក (PHs) សម្របសម្រួលដោយ មន្ត្រីក សិកម្មស្រុក មានរយៈពេល ២ ថ្ងៃ។ តាមការអង្កេតពេលរៀន និងអនុវត្តឃើញថា ៨០ % នៃអ្នកចូលរួមមាន ការយល់ ដឹង បានល្អ។

▪ ជនបង្គោលចំនួន ១១ នាក់ ស្រី ៣ នាក់ និងបុគ្គលិកចំនួន ៦ នាក់ ស្រី ៤ នាក់ ទទួលបានវគ្គបណ្តុះបណ្តាលពីរបៀបប្រើឧបករណ៍វាស់ជាតិពុលក្នុងម្ហូបអាហារ និងទឹក(Nitrate Food Tester) សម្របសម្រួលដោយមន្ត្រីកសិកម្មស្រុក មានរយៈពេល ២ ថ្ងៃ។ តាមការអង្កេតពេលរៀន និងអនុវត្តឃើញថា ៨៥ % នៃអ្នកចូលរួមមានការយល់ដឹងបានល្អ។

<u>Outputs 1.2:</u>



▪ សហគមន៍ចំនួន ១៨២០ នាក់ ស្រីចំនួន ១២០៧ នាក់ នៅក្នុងតំបន់គោលដៅបានចូលរួមការផ្សព្វផ្សាយពីការប្រើសារៈធាតុគីមីក្នុងវិស័យកសិកម្ម និងធ្វើរ៉ែមាស។ តាមការសួរសំណួរមុន និងក្រោយវគ្គឃើញថា ៦៨ %នៃអ្នកចូលរួមមានការយល់ដឹងបានល្អ។

▪ កូនសិស្សអនុវិទ្យាល័យចំនួន ៣៩២ នាក់ ស្រី ២៩៩ នាក់បានចូលរួមការផ្សព្វផ្សាយពីការប្រើសារៈធាតុគីមីក្នុងវិស័យកសិកម្ម និងធ្វើរ៉ែមាស។ តាមការសួរសំណួរមុននិងក្រោយវគ្គឃើញថា ៧៨ %នៃអ្នកចូលរួមមានការយល់ដឹងបានល្អ។

<u>Outputs 1.3:</u>

▪ ៣០ % នៃជនបង្គោលចំនួន ៣៦ នាក់ មានចំណេះដឹង និងជំនាញអាចសម្របសម្រួលការប្រជុំ និងផ្សព្វផ្សាយជាមួយសហគមន៍បាន។

▪ ១២ % នៃសហគមន៍ ចំនួន ២៨៥០ នាក់មានការយល់ដឹង និងមានទំនុកចិត្តអាចចែករំលែកទៅដល់សហគមន៍បាន។

<u>Outputs 2.2:</u>

▪ អង្គការអនុផលព្រៃឈើបានទិញ ឧបករណ៍ (PH) ចំនួន ៥ សម្រាប់ពិនិត្យជាតិពុលនៅក្នុងទឹក និងទិញឧបករណ៍ (Nitrate Food Tester) ចំនួន ១ សម្រាប់ត្រួតពិនិត្យ ជាតិពុលក្នុងទឹក និងម្ហូបអាហារ។

បញ្ហាប្រឈមCovid 19 ធ្វើអោយពិបាក ក្នុងការជួបជុំគ្នា។

## ២.២.២ លទ្ធផលសំខាន់ៗរបស់គម្រោង"ជុំនាន់ថ្មី" (New Generation)

- លទ្ធផល ១.១៖ កុមារនិងយុវជនរៀនអំពីបញ្ហាការពារកុមារនិងបញ្ហាសុខភាពផ្លូវភេទជាមួយ ក្លឹបកុមារនិងបណ្តាញយុវជនក្នុងសហគមន៍៖

- កិច្ចប្រជុំបច្ចេកទេសចំនួន ២លើក ដែលបានចូលរួមពីបុគ្គលិកគំរោងជំនាន់ថ្មីចំនួន ៦ នាក់ស្រ្តី១នាក់ជាបុគ្គលិកអង្គការអនុផលព្រៃឈើ បានបង្កើតចំណេះដឹងពីវិធីសាស្រ្តនៃការប្រជុំការបណ្តុះបណ្តាល គោលការណ៍ស្រាវជ្រាវសកម្មភាព និង វិធីសាស្រ្តមិត្តអប់រំមិត្ត។
- លឹបកុមារ និងយុវជន បានរៀបចំកិច្ចប្រជុំចំនួន ២២ មានអ្នកចូលរួម ៤២៣ (ស្រ្តី: ៣៧, បុរស: ៣៣, កុមារី: ២១១, កុមារា: ១៤២) អំពីទម្រង់រំលោភសិទ្ធិកុមារទាំង ៤ តួនាទីក្លឹបកុមារ ប្រវត្តិក្លឹបកុមារ កសាងផែនការបន្ត។ ជាលទ្ធផល សមាជិកក្លឹបកុមារទទួលបានចំណេះដឹងស្តីពីផែនការយុទ្ធសាស្រ្តនិងរចនាសម្ព័ន ក្លឹមកុមារនិងយុវជនរបស់ពួកគេ និងការវិភាគបញ្ហារបស់កុមារសម្រាប់រាយការណ៍ទៅ គ.ក.ន.ក ឃុំ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត។

- លទ្ធផល ១.២៖ កុមារនិងយុវជនមានវិធានការនិងបញ្ចេញសំលេងដើម្បីការពារសិទ្ធិកុមារនិងសិទ្ធិសុខភាពអេស។ អេស។ អរក្នុងសហគមន៍របស់ពួកគេ៖

- ៦៤ កុមារនិងយុវជន (ស្រី: ២៨, ប្រុស: ១៩, កុមារី: ១១, កុមារា: ៦) បានធ្វើមិត្តអប់រំមិត្តចំនួន ១៦ លើក ដល់ មនុស្សចំនួន៣៦៨ (ស្រី: ៣១, ប្រុស: ២២, កុមារី ១៣៧, កុមារា: ១៧៨) ពីសិទ្ធិកុមារទាំង ៤ (សិទ្ធិរស់រានមានជីវិត សិទ្ធិការពារ សិទ្ធិអ្នកចូលរួមនិងសិទ្ធិក្នុងការអភិវឌ្ឍ) និងទម្រង់សិទ្ធិរំលោភបំពាន (រំលោភបំពានរាងកាយ ការរំលោភបំពានផ្លូវភេទនិងការមិនអើពើ) និងម្យ៉ាងវិញទៀតពួកគេបានអប់រំអំពីផលប៉ះពាល់អវិជ្ជមានពីការឈប់រៀនសូត្រ។
- កុមារនិងយុវជនចំនួន ២៨ នាក់ស្រី ១៤ នាក់ បានដំដែងសំលេងស្នូរជួញចំនួន ២ លើកនៅឃុំតាវែងក្រោមនិងឃុំកោះពាក្យអំពីផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍វ័យកុមារអ្នកចូលរួមទស្សនាចំនួន ១១៦ នាក់ (ស្រី: ៥៣, ប្រុស:៤៤, កុមារី: ១០, កុមារា: ៩) ។មេឃុំបានលើកឡើងអំពីការរៀបការវ័យកុមារនៅកើតឡើងនៅក្នុងសហគមន៍ ហើយ

វាប៉ះពាល់ដល់សិទ្ធិកុមារ។ ៧០% នៃអ្នកចូលរួម ១១៦ នាក់បានយល់អំពីផលប៉ះពាល់អវិជ្ជមានពីពាហ៍ពិពាហ៍កុមារ។

- កុមារនិងយុវជនចំនួន ៣៩ នាក់ ស្រី ២២ នាក់ បានធ្វើការស្រាវជ្រាវនៅឃុំភ្នំកុក ឃុំលុងឃុង និងឃុំ ម៉ាលិក។ ពួកគេបានរកឃើញអាពាហ៍ពិពាហ៍ក្មេងចំនួន ៣០ នាក់ ១៥-១៧ កុមារ ៣០ នាក់និងក្មេងស្រី ១៣ នាក់អាយុ ១៣-១៤ ឆ្នាំធ្វើកម្មករចម្ការកៅស៊ូ ហើយពួកគេធ្វើការនៅពេលយប់ហើយប្រឈមនឹងការបោះបង់ការរៀនសូត្រ ប៉ះពាល់សុខភាព ប៉ះពាល់ដល់សិទ្ធិកុមារទាំង៤ (សិទ្ធិរស់រានមានជីវិតសិទ្ធិក្នុងការចូលរួមសិទ្ធិក្នុងការការពារនិងសិទ្ធិក្នុងការអភិវឌ្ឍ) ។ ក្មេងប្រុស ៤០ នាក់បានប្រើប្រាស់គ្រឿងញៀនដែលមានអាយុពី ១៦-១៧ ឆ្នាំ។
- គ.ក.ន.ក ឃុំ សមាជិកក្លឹបកុមារនិងយុវជនមានចំនួន ៤៦៧ នាក់ (ស្រី: ១៥៨, ប្រុស: ២៤១, កុមារី: ៤០, កុមារា: ២៨) បានចូលរួមប្រជុំចំនួន ២១ នៅថ្នាក់ឃុំនិងស្រុក។ កុមារ និងយុវជន បានរាយការណ៍ពីកុមារប្រមាណ ៣០ នាក់ធ្វើការជាកម្មករកៅស៊ូដើម្បីរកប្រាក់នៅពេលយប់។ គ.ក.ន.ក ឃុំបានធ្វើការណែនាំដល់ឪពុកម្តាយរបស់ពួកគេអំពីសិទ្ធិកុមារ។ ស្ត្រីម្នាក់សម្រាលកូននៅផ្ទះដោយឆ្មបបុរាណ។ គ.ក.ន.ក ឃុំបានព្រមព្រៀងជាមួយឆ្មបបុរាណម្បីបញ្ឈប់បង្កើតកូន។ ក្មេងទំនើង២៥ នាក់អាយុប្រហែល ១៦-២៤ ឆ្នាំ ៣ ករណីលើអំពើហឹង្សាក្នុងគ្រួសារទៅលើកុមារ (វាយលើរាងកាយកុមារស្តីបន្ទោសនិងគំរាម ) អាយុ ១៣-១៧ ឆ្នាំ (ក្មេងស្រី ២ នាក់និងប្រុស ៣ នាក់) និងអាពាហ៍ពិពាហ៍កូន ៣ នាក់មានអាយុ ១៥ ឆ្នាំ។

- <u>លទ្ធផល ២.១ </u>៖ ក្រុមគ្រួសារសមាជិកសហគមន៍និងអ្នកដឹកនាំក្នុងតំបន់បានបង្កើនការយល់ដឹងអំពីសិទ្ធិកុមារ និងទំនួលខុសត្រូវរបស់ពួកគេក្នុងការលើកកម្ពស់សមភាពះ

- វគ្គបណ្តុះបណ្តាលចំនួន ១៥ វគ្គដល់ឪពុកម្តាយ ៣០២ នាក់ (ស្ត្រី: ១៧៣ បុរស: ១២៩) ស្តីពីកាតព្វកិច្ចនិងកាតព្វកិច្ចរបស់មាតាបិតាការអប់រំវិជ្ជមាន ផលប៉ះពាល់អវិជ្ជមានលើការប្រើប្រាស់គ្រឿងញៀន និងការប្រាស្រ័យទាក់ទងក្នុងគ្រួសារ។ ក្រោយការធ្វើតេស្តមានមនុស្ស ១០០ នាក់បានយល់ច្បាស់ និង ១៦០ នាក់បានយល់មធ្យមហើយ ៤២នាក់យល់បន្តិចបន្តួច។
- ក្រុមឪពុកម្តាយចំនួន ២៣៧ នាក់ (ស្ត្រី: ១៤៣,បុរស: ៩៤) បានប្រជុំចំនួន ១៧ ។ ពួកបានចែករំលែកបទពិសោធន៍ពីការអនុវត្តអហិង្សាក្នុងគ្រួសារនិងដំណោះស្រាយនៃបញ្ហានានាកើតឡើង។ ពួកគេបានលើកឡើងនូវករណីមួយចំនួនដូចជាកុមារ ១០ នាក់អាយុ ១៦-១៨ ឆ្នាំជាក្មេងទំនើង ៩ នាក់រៀបការវ័យកុមារ អាយុ ១៥-២០ ឆ្នាំ ៨ នាក់ប្រើប្រាស់គ្រឿងញៀនមានអាយុ ១៦-២៣ ឆ្នាំ ហើយស្ត្រី ១ នាក់ឆ្លងទន្លេតាមប្រពៃណី។

- បណ្ដុះបណ្ដាលចំនួន ១៣ វគ្គដល់ ២២៨បណ្ដាយថ្នាក់ភូមិ (ស្ត្រី ៨៦ នាក់បុរស ១៣៣ នាក់ក្មេងស្រី ៩ នាក់) ស្ដីពីជីវិតជាឪពុកម្ដាយ កាតព្វកិច្ចរបស់ឪពុកម្ដាយចំពោះកូន និងកាតព្វកិច្ចរបស់កូន ៗ ចំពោះឪពុកម្ដាយ។ ផ្អែកលើលទ្ធផលក្រោយការធ្វើតេស្តនៃការបណ្ដុះបណ្ដាល ត្រូវបានគេរកឃើញថាមាន ១៥% បានយល់ច្បាស់ហើយ ៨៥% នៃអ្នកចូលរួមចំនួន ២២៨ នាក់បានយល់ជាមធ្យមអំពីជីវិតជាឪពុកម្ដាយកាតព្វកិច្ចរបស់ឪពុកម្ដាយចំពោះកូននិងកាតព្វកិច្ចរបស់កុមារចំពោះឪពុកម្ដាយ។
- ៨៩ ភូមិបានប្រជុំមានអ្នកចូលរួមចំនួន 108 (ស្ត្រី: 433, បុរស: 579, កុមារី: 42, កុមារា: 30) ស្ដីពីការពិនិត្យឡើងវិញតួនាទីរបស់ បណ្ដាញថ្នាក់ភូមិ និងសមាសភាពសមាជិករបាយការលទ្ធផលបានអនុវត្ត បញ្ហាទាក់ទងនឹងការរំលោភសិទ្ធិកុមារ និងកសាងផែនការសកម្មភាពបន្ត។ ពួកគេបានរាយការណ៍អំពីបញ្ហាដែលបានកើតឡើងនៅក្នុងសហគមន៍របស់ពួកគេដូចជា កុមារ៤ នាក់គ្មានសំបុត្រកំណើត កុមារ១៥ នាក់បានប្រើប្រាស់និងចែកចាយថ្នាំញៀនដែលមានអាយុចន្លោះពី ១៦-២៤ ឆ្នាំ ការរៀបការរែកុមារមាន ៤ ករណី ៧ករណីពើហិង្សាលើកុមារអាយុ ៦ -១៣ ពីឪពុករបស់ពួកគេឥឡូវនេះ គ.ក.ន.ឃុំ បានណែនាំដល់បុរសទាំងពីរនាក់ដោយការព្រមានពាក្យសំដី។
- <u>លទ្ធផល ២.២</u> ៖ ក្រុមគ្រួសារសមាជិកសហគមន៍និងអ្នកដឹកនាំសហគមន៍គាំទ្រសកម្មភាពនានាដើម្បីលើកកម្ពស់សិទ្ធិនិងសមភាពសម្រាប់ក្មេងស្រី៖
- ឪពុកម្ដាយចំនួន ៥0 នាក់ (ស្ត្រី: 27, បុរស: 23) បានធ្វើការអប់រំមិត្តអប់រំមិត្តបាន ១៥ ដងដល់ មនុស្សចំនួន២៤៩ (ស្ត្រី: ១៤៥, បុរស: ៩១, កុមារី: ៧, កុមារា: ៦) អំពីកាតព្វកិច្ចមាតាបិតា (១៣ ជំហាន) និងភារកិច្ច នៃកុមារ (៩ ជំហាន) និងការគ្រប់គ្រងកំហឹងបានរកឃើញថាមានអ្នកចូលរួម ៧៤ នាក់ ស្រី ៤៤ នាក់បានយល់មធ្យម ហើយអ្នកចូលរួមចំនួន ១៧៥ នាក់ផ្សេងទៀតបានយល់តិចតួច។ ដូច្នេះអ្នកអប់រំមិត្ត និងគ្រោងធ្វើបន្តជាមួយអ្នកទាំងនោះទៀត។
- ការប្រជុំ ១២លើ របស់ក្រុមឪពុកម្ដាយដែលមាន ២១២ (ស្ត្រី: ៥៨, បុរស ១៤៤, កុមារី: ៦ , កុមារា: ៤) ពីតួនាទីរបស់ក្រុមឪពុកម្ដាយការ ចែករំលែកបទពិសោធន៍ដើម្បីការពារការរំលោភបំពានក្នុងគ្រួសារ ធ្វើបច្ចុប្បន្នភាព កសាងផែនការធ្វើផែនការបន្ត។ ពួកគេបានពិនិត្យមើលតួនាទីរបស់ពួកគេ និងចែករំលែកបទពិសោធន៍ស្ដីពីការការពារអំពើហិង្សាក្នុងគ្រួសារ ហើយបន្ទាប់មកពួកគេបានរាយការណ៍អំពីបញ្ហាក្មេងទំនើងចំនួន ១០ នាក់ដែលមានអាយុចន្លោះពី ១៦-២៣ ឆ្នាំ។ ឥឡូវប៉ូលីសនិងគ.ក.ន.ក ឃុំនិងចុះអង្កេតបញ្ហាទាំងនោះ។

- កិច្ចប្រជុំចរចារថ្នាក់ភូមិចំនួន ១២លើក ដើម្បីពិភាក្សារវាងក្រុមឪពុកម្តាយនិងកុមារដែលមានអ្នកចូលរួមចំនួន ២៩៨ នាក់ (ស្ត្រី: ១៨៥, បុរស: ៩៤, កុមារី: ១៤, កុមារា: ៥) ។ អ្នកចូលរួមបានចែករំលែកបទពិសោធន៍ស្តីពីកាតព្វកិច្ចរបស់ឪពុកម្តាយចំពោះកុមារដូចជាផ្តល់អាហារសម្លៀកបំពាក់ស្លៀកសំបុត្រកំណើត និងករណីកិច្ចកូន ។ ចំពោះឪពុកម្តាយដូចជាចេះស្រឡាញ់គ្រួសារ ជួយការងារផ្ទះ។ក្នុងនោះមានអ្នកចូលរួមចំនួន ២៩៨ នាក់បានយល់ច្បាស់អំពីតួនាទីរបស់ពួកគេ។
- ៨១ភូមិបានរៀបចំផ្សព្វផ្សាយថ្នាក់ភូមិមានអ្នកចូលរួម ៤៨០ (ស្ត្រី: ២០៣, បុរស: ១៧១, កុមារី: ៧៦ កុមារា: ៣០) ស្តីពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍វ័យកុមារ ការចូលរួមរបស់កុមារ និងសមភាពយេនឌ័រ។ អ្នកចូលរួមបានធ្វើការពិភាក្សាជាក្រុមអំពីផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍កុមារការសិទ្ធិចូលរួមរបស់កុមារ និងសមភាពយេនឌ័រ ។លទ្ធផលតាមការសង្កេតឃើញថា ៤០% មានការយល់ដឹងជាមធ្យមហើយ ៦០%មានការយល់ដឹងតិចតួច ដូច្នេះប្រធានបណ្តាញថ្នាក់ភូមិ និងគម្រោងធ្វើការអប់រំជាមួយសមាជិកសហគមន៍ទាំងនោះតាមរយៈការប្រជុំក្រៅផ្លូវការនិងការប្រជុំផ្លូវការ។
- <u>លទ្ធផល ២.៣</u> ៖ CBO (ក្លឹបកុមារ ក្រុមឪពុកម្តាយ បណ្តាញភូមិ,យុវជន និង CBOs ផ្សេងទៀត) ចេះធ្វើការរួមគ្នានៅថ្នាក់ឃុំ៖
- CBOs បានធ្វើការប្រជុំចំនួន ៤លើកមានអ្នកចូលរួមចំនួន ១៦ (ស្ត្រី: ១១ បុរស: ៥,) អ្នកទាំងនោះគឺក្លឹបកុមារ ក្រុមឪពុកម្តាយ ការធ្វើមាតាបិតាលើការពិភាក្សាតួនាទីរបស់ CBO បណ្តាញសហគមន៍ចូលរួមសកម្មភាព។ ពួកគេបង្កើតតួនាទី CBOs យន្តការរាយការណ៍បញ្ហាទៅប៉ូលីសមេឃុំ គ.ក.ន.ក ថ្នាក់ឃុំ និង ស្រុក ក្រុមបណ្តាយភូមិ និងក្រុមឪពុកម្តាយ ថែទាំក្លឹបកុមារ និង ពួកគេចេះចូលរួមសកម្មភាពរួមគ្នាក្នុងដាក់ឥទិពលដល់អាជ្ញាធរពាក់ព័ន្ធអនុវត្តតួនាទីរបស់គេ។
- <u>លទ្ធផល ៣.១</u> ៖ រដ្ឋាភិបាលថ្នាក់ក្រោមជាតិនិងសង្គមស៊ីវិលយល់ពីទំនួលខុសត្រូវរបស់ខ្លួនក្នុងនាមជាអ្នកមានកាន់កាតព្វកិច្ច និងប្តេជ្ញាចិត្តក្នុងការធានាការការពារកុមារនិង និងសុខភាពផ្លូវភេទ៖
- តំណាងអង្គការសង្គមស៊ីវិលថ្នាក់ខេត្តចំនួន ១១នាក់ បានធ្វើការប្រជុំចំនួន ១លើក ដែលមានអ្នកចូលរួមចំនួន ១១ នាក់ស្រី ២ នាក់ ពិភាក្សាអំពីលទ្ធផលដែលបានអនុវត្ត រួមមានក្រុមបណ្តាញយុវជនបានរៀបចំយុទ្ធនាការ ១៦ ថ្ងៃដើម្បីការពារអាពាហ៍ពិពាហ៍កុមារ។ អង្គការYES បានកសាងសមត្ថភាពដល់យុវជនក្នុងនាមជាភាពជាអ្នកដឹកនាំ អង្គការUWS បានធ្វើយុទ្ធនាការផ្សព្វផ្សាយដើម្បីបញ្ឈប់ការរៀបការវ័យកុមារ អង្គការ NTFP បានកសាងសមត្ថភាពដល់កុមារយុវជនសហគមន៍អំពីការការពារសិទ្ធិកុមារ។

អង្គប្រជុំបានលើកឡើងថា មានអង្គការសង្គមស៊ីវិលចំនួន ១៥ ដែលធ្វើការលើកុមារនិងយុវជន ផ្តោតលើកកំពស់សិទ្ធិនិងការអភិវឌ្ឍន៍។

- ផ្តល់វគ្គបណ្តុះបណ្តាលបាន១លើក ដល់តំណាងអង្គការសង្គមស៊ីវិលចំនួន ២០ នាក់ ដែលមានស្រ្តី ៩ នាក់ ពីឆ្លើយតបនឹងយេនឌ័រនៃសេវាសង្គម។ បានធ្វើបទបង្ហាញអំពីសិទ្ធិកុមារការ ការការពារកុមារ និងការអភិវឌ្ឍយុវជន និងបង្ហាញអំពីរចនាសម្ព័ន្ធសេវាកម្មសង្គមឆ្លើយតបពីគណៈកម្មាធិការកុមារនិងស្ត្រីនៃស្រុកនិងខេត្តដែលទាក់ទងបញ្ហាយេនឌ័រ និងបង្ហាញពីច្បាប់ពាក់ព័ន្ធផ្សេងទៀតលើបញ្ហាយេនឌ័រ។ អ្នកចូលរួមបានធ្វើការពិភាក្សាអំពីសិទ្ធិរបស់កុមារទាំង៤ប្រភេទ រចនាសម្ព័ន្ធសេវាកម្មសង្គមដូចជា ក្រុមការងារអង្គការសង្គមស៊ីវិល បណ្តាញយុវជន ហើយជាលទ្ធផលវាយតំលៃឃើញថា ៦០%បានយល់ច្បាស់ ហើយ៤០%បានយល់មធ្យម។
- សហគមន៍ស្ម័គ្រចិត្តសង្គមកិច្ចចំនួន៣៩នាក់មានស្ត្រីចំនួន១២នាក់ បានចូលរួមប្រជុំថ្នាក់ស្រុកចំនួន ៨លើក ពួកគេបានពិភាក្សាអំពីតួនាទី សមិទ្ធិផលសំរេចបាន បញ្ហាប្រឈម និងការបង្កើតផែនការសកម្មភាពសម្រាប់ខែបន្ទាប់។ តាមរយៈការពិភាក្សាជាក្រុមបានរកឃើញថាសហគមន៍ស្ម័គ្រចិត្តសង្គមកិច្ចចំនួន ២០នាក់ បានយល់ច្បាស់ ហើយ១៩នាក់បានយល់ដឹងមធ្យមអំពីតួនាទីរបស់ពួកគេ។ ពួកគេបានកំណត់បញ្ហាប្រឈម និងធ្វើផែនការសំរាប់ខែបន្ទាប់។សហគមន៍ស្ម័គ្រចិត្តសង្គមកិច្ចបានសម្ភាសជនរងគ្រោះចំនួន ១ នាក់ ហើយនាងបានស្នើសុំដល់អាជ្ញាធរនិងអ្នកពាក់ព័ន្ធបានជួយអន្តរាគមន៍ដល់ឪពុកនាងបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ។ ឥឡូវប្រធានបណ្តាញភូមិបានធ្វើលិខិតព្រមព្រៀងជាមួយបុរសនោះ។
- សហគមន៍ស្ម័គ្រចិត្តសង្គមកិច្ចចុះសិក្សាស្រាវជ្រាវបានរកឃើញ ករណីផ្លូវភេទ៖ ២ករណីនៅភូមិយ៉ែមឃុំសើង ២ ករណីនៅភូមិកែត ឃុំញ៉ាង និង ២ ករណីនៅភូមិតាង៉ាចឃុំតាវែងក្រោមនិង ១ ករណីទៀតនៃអំពើហិង្សាក្នុងគ្រួសារនៅភូមិរឿងចាន់ឃុំតាវែងក្រោម។

- <u>លទ្ធផល ៣.២</u> ៖ រដ្ឋាភិបាលថ្នាក់ក្រោមជាតិនិងស្ថាប័នសង្គមស៊ីវិលអភិវឌ្ឍ / ពង្រឹងប្រព័ន្ធការពារកុមារនិងយុវជន និងលើកកម្ពស់ការចូលរួមរបស់ពួកគេនៅក្នុងសង្គម៖

- បុគ្គលិកគម្រោងសម្របសម្រួលជាមួយស៊ី.ស៊ី.ស៊ី.ស៊ីនៅឃុំចំនួន ៣ នៃស្រុកប៉ាឡាឡាក់ ឃុំតាវែងលើនិងឃុំសៀង ២៤ (ប្រុស ៦ នាក់ស្រី ១៧ នាក់) បានពិនិត្យមើលផែនទីសេវាកម្មសង្គមនិងបានរកឃើញថាបញ្ហាលើកុមារកំព្រាប្រឈមនឹងកង្វះលំនៅដ្ឋានសម្ភារៈសិក្សាអាហារនិងសម្លៀកបំពាក់។ សុខភាពរបស់ស្ត្រីដោយការធ្វេសប្រហែសនិងកំណើតកូននៅផ្ទះ។ គ្រួសារមួយចំនួនតូចនៃសហគមន៍ខ្វះបង្គន់អនាម័យកុមារខ្លះ

មិនមានលិខិតបញ្ជាក់កំណើតការប្រើអំពើហិង្សាក្នុងគ្រួសារការរៀបការកូនក្មេងដំបូង។ អាជ្ញាធរមូលដ្ឋានបានប្តេជ្ញាជំរុញឱ្យមេភូមិផ្សព្វផ្សាយដល់អ្នកភូមិហើយពួកគេគ្រោងនឹងបញ្ចូលវាទៅក្នុងស៊ីអាយភី។

- រៀបចំកិច្ចប្រជុំថ្នាក់ស្រុកចំនួន ៤លើក ដែលមានការចូលរួមចំនួន ៥៧ (ប្រុស: ២៦, ស្ត្រី: ២០, កុមារា: ៤, កុមារី: ៧) ក្នុងគោលបំណងពិភាក្សាអំពីការឆ្លើយតបនិងបញ្ហាយេនឌ័រពីគ.ក.ន.ក ឃុំ ស្រុក និងខេត្ត ។ ពួកគេបានរាយការណ៍អំពីអំពើហឹង្សាតាមមូលដ្ឋានបានកើតឡើងដូចជា កុមារ ស្ត្រីទទួលរងអំពើហឹង្សា (ខាំលើរាងកាយគំរាមកំហែងនិងស្តីបន្ទោសការប្រើអំពើហឹង្សាក្នុងគ្រួសារ) ក្មេងស្រីប្រឈមនឹងការរំលោភបំពានផ្លូវភេទ ។ គ.ក.ស.ក ស្រុកបានបង្ហាញ អំពីច្បាប់ទាក់ទងនឹងបញ្ហាយេនឌ័រ ត្រូវរាយការណ៍ទៅកាន់គ.ក.ស.ក ស្រុកនិងខេត្ត តាមទូរស័ព្ទ។ គ.ក.ស.ក ស្រុកបានលើកឡើងថាជនរងគ្រោះបានទទួលជំនួយដូចជាចំណីអាហារឧបករណ៍ (អង្ករ) ថ្លៃដំណើរ ថ្លៃព្យាបាល និងការគាំទ្រផ្នែកច្បាប់។ អ្នកចូលរួមដឹងអំពីសេវាកម្មគាំទ្រដល់ជនរងគ្រោះពីអំពើហឹង្សាប្រឆាំងនឹងកុមារ និងស្ត្រី។

## ២.២.៣ លទ្ធផលគម្រោង"បញ្ឈប់អាពាហ៍ពិពាហ៍លើកុមារ"

- <u>សកម្មភាព ២.២</u> ៖ គាំទ្រការប្រជុំទៀងគ.ក.ន.កឃុំក្នុងការតតាមដានការប្រឆាំងការរៀបអាពាហ៍ពិពាហ៍វ័យកុមារ : គ.ក.ន.ក ចំនួន៩ឃុំបានប្រជុំចំនួន៦៨លើកមានអ្នកចូលរួម ៩១០ នាក់ (ប្រុស ៦១៤ នាក់ស្រី ២៩៥ នាក់និងក្មេងស្រី ១ នាក់) ដែលជាអាជ្ញាធរឃុំមេភូមិ ចាស់ទុំតំណាងកុមារ តំណាងយុវជន ប៉ុស្តិ៍ប៉ូលីស មានលទ្ធផលដូចខាងក្រោម៖

- អ្នកចូលរួមបានកំណត់តួនាទីរបស់ CWCC, ក្លឹបកុមារ ដើម្បីការពារអាពាហ៍ពិពាហ៍វ័យកុមារ និងលើកកំពស់សិទ្ធិកុមារ។ តួនាទីរបស់ពួកគួរមមានផ្សព្វផ្សាយច្បាប់និងគោលនយោបាយ ស៊ើបអង្កេតអំពើហិង្សាកា រសហការនិងរាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន ការបញ្ជ្រាបផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍វ័យកុមារ ។ តាមរយៈការប្រជុំភូមិ និងពិធីបុណ្យក្នុងភូមិអាពាហ៍ពិពាហ៍កុមារប្រឈមនឹងបញ្ហាជាច្រើន ដូចជា បញ្ហាសុខភាព បញ្ហាសេដ្ឋកិច្ច និងអសន្តិសុខសង្គម។ ក្នុងចំណោមបញ្ហាទាំងនោះមានដូចជាបញ្ហាសុខភាពការកើនឡើង នូវមរណភាព និងការលែងលះ ហើយបន្ទ្រីមណ្ឌលសុខភាពបានលើកឡើងថាសហគមន៍មូលដ្ឋានមានស្ត្រីវ័យជំទង់ជាច្រើនបានប្រឈម និងកូនសំរាលកូនព្រោះភាគច្រើនមិនបានពិនិត្យសុខភាពជាប្រចាំ និងមិនអនុវត្តតាមគោលការណ៍សុខភាព ហើយស្ត្រីមួយចំនួននៅតែសម្រាលកូននៅផ្ទះ។ ដូច្នេះមេភូមិ

ទាំងអស់បានចែករំលែកព័ត៌មាននេះដល់សហគមន៍ត្រូវពិនិត្យសុខភាពជាប្រចាំ។លោកគ្រូអ្នកគ្រូបានលើកឡើងថាមានសិស្សមួយចំនួនតូចគ្មានសំបុត្រកំណើត ដូច្នេះឪពុកម្តាយទាំងអស់ត្រូវធ្វើសំបុត្រកំណើតមុនពេលបញ្ជូនទៅសាលារៀន។សិក្ខាកាមទាំងអស់បង្កើនចំណេះដឹងដើម្បីកំណត់បញ្ហាធំ ៗ ដែលទាក់ទងនឹងការការពារនិងការពារសិទ្ធិកុមារជាពិសេសសុខភាពបន្តពូជ សុខភាពផ្លូវភេទ និងការប្រជុំរួមរបស់គ.ក.ន.កឃុំ ស្តីពីសិទ្ធិកុមារនិងសុខភាពបន្តពូជសម្រាប់សិទ្ធិពិភាក្សាដើម្បីរកអន្តរាគមន៍។

- <u>សកម្មភាព ២.៤.២</u> ៖ គាំទ្រសេវាសុខភាព :

- មណ្ឌលសុខភាពចំនួន៦ បានទទួលឧបករណ៍សង្គ្រោះបន្ទាន់ពីគម្រោងហើយ ពួកគេបានសហការក្រុមនាំដោយក្មេងស្រី បានធ្វើប្រឹក្សាយោបល់ចំនួន ១៣ ដង លើការផ្តល់ការប្រឹក្សាយោបល់តាមរយៈការចុះសួរសុខទុក្ខតាមផ្ទះចំពោះការរៀបការវ័យកុមារចំនួន ៧៨ នាក់ ដែលប្រឈមនឹងបញ្ហាសុខភាព។ មណ្ឌលសុខភាពទាំង ចំនួន ៦ បានអប់រំដល់ក្មេងស្រី ពីអនាម័យរបៀបថែទាំមុននិងក្រោយពេលសម្រាលកូន របៀបយកូនតាមតម្រូវការ ប្រាប់កន្លែងព្យាបាលដែលនៅជិត។ ហើយរហូតមកដល់ពេលនេះមានស្ត្រី ៧០%ស្ត្រី ៧៨នាក់បានចាប់ផ្តើមមានផែនការពិនិត្យទៀងទាត់នៅពេលពួកគេមានផ្ទៃពោះ។ មន្ត្រីមជ្ឈមណ្ឌល សុខភាពទាំង៦បានអនុវត្តតួនាទីរបស់ពួកគេបានល្អប្រសើរ ក្នុងការលើកកម្ពស់សេវាសុខភាពដល់សហគមន៍ហើយម្យ៉ាងវិញទៀតពួកគេបានទទួលបទពិសោធន៍ជាច្រើនពីការសហការជាមួយក្រុមដឹកនាំដោយក្មេងស្រីចំពោះមនុស្សវ័យជំទង់និងក្មេងស្រីមានផ្ទៃពោះ មានភាពក្លាហាន និយាយអំពីបញ្ហាសុខភាពរបស់ពួកគេ។
- បុគ្គលិកគម្រោងបានសហការជាមួយគ.ក.ន.ក មណ្ឌលសុខភាពដើម្បីជួយសង្គ្រោះក្មេងស្រី ៣ នាក់ដែលមានបញ្ហាសុខភាពពីការរៀបការកូនក្មេង។ ឥលូវនេះក្មេងស្រីទាំងនេះមានសុខភាពល្អប្រសើរ ហើយពួកគេចាប់ផ្តើមអនុវត្តការថែរក្សាសុខភាពតាមការណែនាំគ្រូទេព្យ។ សហគមន៍ភាគច្រើនចាប់ផ្តើមប្រើវិធីថែទាំសុខភាពទាំងជំនឿប្រពៃណីនិងការថែទាំវេជ្ជសាស្ត្រ។

- <u>សកម្មភាព ៣.១.១</u> ៖ ចាក់វីដេអូតាមភូមិ :

ក្រុមដឹកនាំដោយក្មេងស្រីនិងក្រុមមនុស្សចាស់ បានចាក់ផ្សាយវីដេអូបានចំនួន ៣៧កន្លែង មានអ្នកចូលរួមចំនួន ២៣១២ (បុរស ៧០៥ នាក់ស្រី ៧០៤ នាក់ កុមារា ៤២១ នាក់កុមារី ៤៨២ នាក់) ។ វីដេអូបង្ហាញអំពី រឿងនៃអំពើហឹង្សាក្នុងគ្រួសារការ អំពើហឹង្សាប្រឆាំងនឹងកុមារ។សេចក្តីសន្និដ្ឋានតាមរយៈសំណួរបំផុសគំនិតបានរកឃើញថាមានអ្នកចូលរួម ៧០% បានយល់អំពីការរំលោភសិទ្ធិកុមារ កាតព្វកិច្ចមាតាបិតាចំពោះកុមារនិងកាតភារកិច្ច

របស់កុមារចំពោះឪពុកម្តាយ និងម្យ៉ាងវិញទៀតពួកគេអាចចេះរិភាគលើ សកម្មភាពដែលគោរពសិទ្ធិកុមារ ដែលផ្អែកលើគោលការណ៍សិទ្ធិកុមារនៅកម្ពុជានិង UNCRC ។

- សកម្មភាព ៣.២.១ ៖ បញ្ជាក់ពីក្រុមគ្រួសារដែលមានហានិភ័យនិងប្រមូលព័ត៌មានអំពីអាពាហ៍ពិពាហ៍របស់កុមារដើម្បីចូលរួមក្នុងការសម្តែង :

ក្រុមដឹកនាំដោយក្មេងស្រីបានចុះកំណត់គ្រួសារដែលមានហានិភ្យ ចំនួន ២៩៩ នាក់ (៨៥ នាក់ស្រី ១០១ ក្មេងប្រុស ៧៩ នាក់ស្រី ៣៤) ក្នុងឃុំគោលដៅឃុំចំនួន៩។ មានគោលបំណងជ្រើសរើសពួកធ្វើជាតួ សំដែងរឿងស្តីពីរបៀបចិញ្ចឹមកូនរបស់ពួកគេ។

ចុងក្រោយពួកគេអាចបង្កើតផែនការសម្រាប់ផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់សហគមន៍របស់ពួកគេតាមភូមិ។

- សកម្មភាព ៣.២.២ ៖ ការបញ្ជ្រាបនៅក្នុងការប្រជុំភូមិនៅរៀងរាល់ត្រីមាសដោយក្មេងជំទង់ : គ.ក.ន.ក ក្រុមក្មេងស្រី និងសមាជិកក្លឹបកុមារ ក្រុមចាស់ទុំ ជាក្រុមទទួលផលផ្ទាល់ ចំនួន៣៧៥ នាក់ (បុរស ១៩៤ ស្ត្រី ១៦២ កុមារា ៥ នាក់កុមារី ១៤ នាក់) ក្រុមទទួលផល មិនផ្ទាល់ចំនួន ៣២៣ នាក់ (បុរស ១៤៨ ស្រី ១ កុមារា ២ នាក់និងកុមារី ២ នាក់) បានប្រជុំ ២៨ នៅតាមភូមិ ពិភាក្សា (១) សិទ្ធិកុមារ (២) អាពាហ៍ពិពាហ៍ (៣) ផលប៉ះពាល់អវិជ្ជមាន ពីអាពាហ៍ពិពាហ៍កុមារ។លទ្ធផលក្រុមស្រី និងតំណាងក្លឹបកុមារបានលើកឡើងពី ការរំលោភលើសិទ្ធិកុមារ ៤ប្រភេទ (ការរំលោភបំពានលើរាងកាយ ការរំលោភបំពានផ្លូវភេទ ការរំលោភបំពានផ្លូវចិត្ត និងការព្រងើយកន្តើយ) ។ពួកគេបានលើកឡើងអំពីកុមារមួយចំនួនបានរៀបការតាំងពីអាយុ ១៣ ឆ្នាំដល់ អាយុ ១៧ ឆ្នាំ មាន ១៤៣ នាក់ក្នុង ៧ ឃុំនៅស្រុកវើនសៃ និងស្រុកអូរជុំ។

- សកម្មភាព ៣.២.៣៖ សំដែងរឿង :

ក្រុមដឹកនាំដោយកុមារី និងក្រុមចាស់ទុំបានអនុវត្តការសម្តែងរឿងចំនួន ១៨ កន្លែងចូលរួមចំនួន ១៣៦៥ (បុរស ៣៤២នាក់ ស្ត្រី ៥៧៧នាក់ កុមារា ៣២៥នាក់ និងកុមារី ១២១ នាក់) រឿងស្តីអំពីការធ្វើជាឪពុកម្តាយវិជ្ជមាន ផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍កុមារ។

ដោយផ្អែកលើការវាយតំលៃទៅលើការយល់ដឹងរបស់អ្នកចូលរួមបានរកឃើញថាពួកគេទាំងអស់មានការយល់ដឹងមធ្យមអំពីការធ្វើជាឪពុកម្តាយវិជ្ជមាននិង សិទ្ធិកុមារ ផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍កុមារ។

- សកម្មភាព ៣.៤ ៖ យុទ្ធនាការផ្សព្វផ្សាយពីតួនាទីឪពុកម្តាយ :

ក្រុមដឹកនាំដោយក្មេងស្រីនិងក្រុកមនុស្សចាស់បានធ្វើយុទ្ធនាការផ្សព្វផ្សាយបានចំនួន១៩ លើកមានអ្នកចូលរួមចំនួន ៣៨៧ នាក់ (បុរស ៥៣ នាក់ស្រី ២៣០ នាក់បកុមារា ២៣

នាក់និងកុមារី ៨១ នាក់) ។ ពួកគេបានយល់ដឹងអំពីភាពជាឪពុកម្តាយវិជ្ជមាន សុខភាពបន្តពូជ និងការការពារសិទ្ធិកុមារ។

- សកម្មភាព ៣.៥.២ ៖ ផ្តល់ជូននូវសេវាកម្ម រួមទាំងការចុះសួរសុខទុក្ខដល់គ្រួសារដែលមានហានិភ័យ។ មណ្ឌលសុខភាពចំនួន៦បានអប់រំដល់អាពាហ៍ពិពាហ៍កុមារដំបូងចំនួន១៩៧នាក់ដែលប្រឈមនឹងបញ្ហាសុខភាពពីអាពាហ៍ពិពាហ៍របស់កុមារ អំពីអនាម័យ,អាហាររូបត្ថម្ភ, ការពារការមានគភ៌, ទាក់ទងប៉ុស្តិ៍សុខភាពដែលនៅជិតបំផុតអំពីផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍របស់កុមារ។ មន្ត្រីប៉ុស្តិ៍សុខភាពសង្កេតឃើញថាមាន មានប្រមាណ៦០ភាគរយមានការយល់ដឹងមធ្យមអំពីអនាម័យនិងការការពារសុខភាពហើយពួកគេបានណែនាំដល់ប្រជាជនទាំងអស់គួរតែបញ្ឈប់ការសម្រាលកូននៅផ្ទះព្រោះវាមានគ្រោះថ្នាក់ខ្លាំងណាស់ទាំងម្តាយនិងទារក។ មន្ត្រីប៉ុស្តិ៍សុខភាពបានរាយការណ៍ថាចាប់តាំងពីពួកគេបានសហការជាមួយគម្រោងនេះបានកត់សម្គាល់ឃើញថាស្ត្រីវ័យក្មេងដែលមានគភ៌បានបង្កើនសកម្មភាពក្នុងការត្រួតពិនិត្យសុខភាពនៅតាមមណ្ឌលសុខភាពផងដែរ។
- សកម្មភាព ៣.៦ ៖ ជ្រើសរើសគ្រួសារគំរូ :

គ្រួសារគំរូចំនួន៩ត្រូវបានជ្រើសរើសផ្អែកលើលទ្ធផលពិន្ទុហើយពួកគេទទួលបានធុងចំរោះទឹកស្អាតមួយសំរាប់១គ្រួសាពីគម្រោង។គម្រោងបានធ្វើការជាមួយពួកគេដើម្បីបង្កើតផែនការចែករំលែកបទពិសោធន៍ទាក់ទងនឹងអាកប្បកិរិយាវិជ្ជមានហើយពួកគេបានចែករំលែកបទពិសោធន៍របស់ពួកគេដល់សហគមន៍ដទៃទៀតតាមរយៈការប្រជុំភូមិចំនួន ២៨ ជាមួយអ្នកភូមិចំនួន ៣២៣ នាក់ (បុរស១៤៨នាក់ស្ត្រី ១នាក់កុមារា២ នាក់និងកុមារីស្រី ២ នាក់) ។

- សកម្មភាព ៤.២.២ ៖ បណ្តុះបណ្តាលកុមារនិងយុវជន :

អ្នកចូលរួមចំនួន ១៩០ នាក់ (ប្រុស ៦២ នាក់ស្រី ១២៤ នាក់កុមារា ៣ នាក់កុមារី១នាក់) ដែលជាសមាជិកក្លឹបកុមារនិងក្រុមដឹកនាំក្មេងស្រីទាំង ៩ឃុំ ទទួលបានវគ្គបណ្តុះបណ្តាលចំនួន ៨ លើ ពី (១) ច្បាប់ពាក់ព័ន្ធក្នុងកិច្ចការពារកុមារ (២) ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ (៣) ការរំលោភសិទ្ធិកុមារ (៤) វិធីសាស្ត្រផ្សព្វផ្សាយ (៥) ជំនាញទំនាក់ទំនង (៦) វីដេអូបង្ហាញអំពីផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍របស់កូនក្មេង, ៧) បន្តពូជសុខភាពត្រឹមត្រូវខាងផ្លូវភេទ, ៨) យេនឌ័រ និងវិធីសាស្ត្រការតស៊ូមតិ (៩) បង្កើតផែនការសកម្មភាពប្រចាំឆ្នាំ។យោងតាមលទ្ធផលការវាយតំលៃចុងវគ្គរកឃើញថា ៧៥% នៃ ១៩០ បានយល់មធ្យម២៥%បានយល់ដឹងតិចតួចនៅឡើង។

- សកម្មភាព ៤.៣.២ ៖ ប្រជុំក្លឹបកុមារ :

ការប្រជុំចំនួន ៦៤លើក ក្នុងចំណោមក្លឹបកុមារចំនួន ១៨ ដែលមានអ្នកចូលរួម ៩០៦ នាក់ (បុរស ១០៥ នាក់ស្រី ២២៧ នាក់ កុមារា ២១៤ នាក់ និងកុមារី ៣៦០ នាក់) ។ គោលបំណងនៃការប្រជុំគឺដើម្បីអភិវឌ្ឍសមត្ថភាពរបស់ពួកគេលើសិទ្ធិកុមារ អាពាហ៍ពិពាហ៍កុមារ គោលនយោបាយពាក់ព័ន្ធនិងច្បាប់ពាក់ព័ន្ធក្លឹបកុមារ និងតួនាទីជាលទ្ធផលបានដូចខាងក្រោមៈ

- កំណត់បញ្ហាដែលទាក់ទងនឹងការរំលោភលើកុមារដែលបានកើតឡើងដូចជាកុមារបោះបង់ចោលការសិក្សា ការរៀបការនៅវ័យក្មេង និងកុមារដែលប្រើប្រាស់គ្រឿងញៀន។តាមរយៈកិច្ចប្រជុំក្លឹបកុមារបានរកឃើញថាកុមារពាក់កណ្តាលនៅក្នុងក្លឹបកុមារយល់អំពីយន្តការរាយការណ៍ យន្តការការពារសិទ្ធិកុមាររួមមានការស៊ើបអង្កេតតាមដានករណីការរាយការណ៍។
- ក្រុមដឹកនាំដោយក្មេងស្រីពិភាក្សាអំពីក្រមសីលធម៌កុមារ យេនឌ័រ ទំរង់រំលោភបំពានសិទ្ធិ គោលនយោបាយនិងច្បាប់ទាក់ទងនឹងការការពារសិទ្ធិកុមារ និងផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍របស់កុមារ។
- ក្លឹបកុមារនិងក្រុមដែលដឹកនាំដោយក្មេងស្រីបានបង្កើតផែនការសកម្មភាពប្រចាំឆ្នាំដើម្បីបញ្ឈប់អាពារអាពាហ៍ពិពាហ៍កុមារ ដូចជាប្រធានបទមួយចំនួនគឺលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍កុមារ ការស៊ើបអង្កេត ចូលរួមការប្រជុំឃុំនិងភូមិ និងរាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន អំពីអំពើហឹង្សាប្រឆាំងនឹងកុមារ។

- <u>សកម្មភាព ៤.៤.២</u> ៖ មិត្តអប់រំមិត្ត :

សមាជិកដែលដឹកនាំដោយក្មេងស្រីចំនួន ៤១៨ នាក់មានស្រី ២៩១ នាក់បានធ្វើការអប់រំបានចំនួន ៧៥ដង ដល់មនុស្សចំនួន ៥៦៦ នាក់ (ប្រុស ១១១ នាក់ ស្ត្រី១៦១ នាក់ កុមារា ១២៥ នាក់និងកុមារិ ១៦៩ នាក់ ពីសិទ្ធិកុមារទាំង៤ ផលប៉ះពាល់អវិជ្ជមានពីអាពាហ៍ពិពាហ៍កុមារ, ផលប៉ះពាល់អវិជ្ជមានពីការបោះបង់ការសិក្សា, ការគាំទ្រសេវាសុខភាព។តាមរយៈការពិភាក្សាបានរកឃើញថាពួកគេបានយល់ច្បាស់អំពី៥០% នៃអ្នកចូលរួម ៥៦៦ នាក់លើប្រធានបទពាក់ព័ន្ធដែលទាក់ទងនឹងសុខភាពផ្លូវភេទបន្តពូជ ការការពារកុមារ និងការចូលរួមនិងម្យ៉ាងវិញទៀតពួកគេក៏បានប្តេជ្ញាចែករំលែកមិត្តភក្តិនៅក្នុងសហគមន៍របស់ពួកគេផងដែរ។

- <u>សកម្មភាព ៤.៥.២</u> ៖ .បុណ្យទិវាស្ត្រី :

បុគ្គលិកគម្រោងធ្វើការសហការជាមួយកិច្ចការនារីខេត្តរតនគិរីបានរៀបចំទិវាសិទ្ធិនារីនៅស្រុកអណ្តូងមាសនិងស្រុកតាវែងដែលមានសមាជិក ២៥ នាក់ជាក្មេងស្រី កុមារា ៧

នាក់និងកុមារី ១៥ នាក់) មកពី ៣ ស្រុក (វើនសៃ តាវែង និងអណ្ដូងមាស និង រួមទាំងសមាជិកសហគមន៍ចំនួន ៥០០ នាក់។លទ្ធផល : សុន្ទរកថារបស់ប្រធានមន្ទីរខេត្ត និងអភិបាលខេត្តបានលើកឡើងអំពីតួនាទីរបស់ស្ត្រីមានសារៈសំខាន់ណាស់ចំពោះការអភិវឌ្ឍដូច្នេះការអភិវឌ្ឍន៍ត្រូវមានការចូលរួមពីបុរសនិងស្ត្រី។

- តំណាងស្ត្រីយ៉ុងបានបង្ហាញពីតួនាទីរបស់ក្មេងប្រុសនិងក្មេងស្រីចូលរួមក្នុងការកសាងសង្គម។
- សាររបស់ព្រះអង្គម្ចាស់មុន្នីនាថសីហានុផ្ដោតលើតួនាទីយេនឌ័រនិងសមភាពយេនឌ័រ។

អ្នកចូលរួម៥៥០០នាក់បានចូលរួមក្នុងទិវានារីយល់អំពីតួនាទីនិងសមភាពយេនឌ័រក្នុងការអភិវឌ្ឍសង្គមហើយបើមិនដូច្នេះទេពួកគេក៏ប្ដេជ្ញានាំសារទាក់ទងនឹងការលើកកម្ពស់តួនាទីយេនឌ័រដើម្បីចែករំលែកដល់សហគមន៍ដទៃទៀត។

## ២.៣.កម្មវិធីអភិវឌ្ឍសហគមន៍និងការអប់រំ (CDE)

### ២.៣.១ លទ្ធផលសំខាន់ៗ របស់គម្រោងអក្ខរកម្ម

ផ្ដល់ការអប់រំពីរភាសាក្នុងខេត្តរតនគីរី

- គ្រូស្ម័គ្រចិត្តសរុបចំនួន៤០នាក់ ស្រី១៣នាក់ និងគ្រូបង្គោលជាបុរសចំនួន៦ នាក់ ត្រូវបានទទួលវគ្គបណ្តុះបណ្តាលពីវិធីសាស្ត្របង្រៀន ចំនួននួន៩វគ្គ។ នៅក្នុងចំណោមអ្នកចូលរៀនទាំងអស់គឺមានអ្នកខ្លះបានចូលរៀនចំនួន៣វគ្គ និងអ្នកខ្លះទៀតចូលបានចំនួន១វគ្គ។ វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដោយប្រើប្រាស់ជាភាសាកាវែតនិងភាសារខ្មែរសម្រាប់ការបណ្តុះបណ្តាល។ គ្រូស្ម័គ្រ័ចំនួន៤០អ្នកបានយកជំនាញពីវិធីសាស្ត្របង្រៀន យកទៅបន្តបង្រៀនបន្តនៅថ្នាក់រាងៗខ្លួនបានបានល្អប្រសើ។
- ថ្នាក់សរុបចំនួន២៣ថ្នាក់ត្រូវបានតាមដានការបង្រៀនចំនួន១៦ដង ហើ្បក្នុងការ តាមដាននោះគឺមាន ថ្នាក់ចំនួន១មិនត្រូវបានដំណើរបង្រៀនទេ ព្រោះគ្រូនិងសិស្សបានធ្វើការផ្លាស់ប្តូរ ទៅធ្វើចំការថ្មីផ្សេងទៀត។
- សូឡាសរុបចំនួន៨ផ្ទាំង ដែលបានដាក់អោយប្រើប្រាស់តាមថ្នាក់ និងមណ្ឌលបណ្តុះបណ្តាលសូឡាទាំងអស់នោះត្រូវបានដាក់ប្រើប្រាស់សម្រាប់គាំទ្រការបង្រៀននៅពេលយប់ ការបង្រៀនកំព្យូរ។
- សិស្សកំព្យូទ័រចំនួន១៦នាក់ ស្រី១២នាក់ ត្រូវបានរៀបចំវគ្គរដ្ឋបាល (Microsoft Word) ហើ្បបច្ចុប្បន្នពួកគេទាំងនោះត្រូវបានចេះប្រើប្រាស់ តែនៅមិនទាន់ចេះប្រើប្រាស់បាន១០០%នៅឡើយទេ។

- សិស្សសរុបចំនួន៩៩២នាក់ស្រី៣២៨ ដែលជាសិស្សអក្ខកម្មថ្នាក់កាវែត និងថ្នាក់ខ្មែរ ត្រូវបាន ចុះឈ្មោះចូលរៀនដើមឆ្នាំ២០២០ ហើយនៅចុងឆ្នាំ២០២០ គឺមានសិស្សបោះបង់ចំនួន២៣នាក់ ក្នុងនោះមានស្រីចំនួន១០ផងដែរ។
- នៅក្នុងឆ្នាំ២០២០ផងដែរមានថ្នាក់ចំនួន២ត្រូវបានរៀនចប់កម្មវិធីអក្ខកម្មរយៈពេល៣ឆ្នាំ ផងដែរ។ ហើយថ្នាក់ដែលនៅសល់នឹងបញ្ចប់នៅចុងឆ្នាំ២០២១និង២០២២។ សិស្សអក្ខរកម្មចំនួន១៧នាក់ត្រូវបានរៀបចប់កម្មវិធីអក្ខរកម្មចំនួន៣ឆ្នាំហើយក្នុងនោះមានសិស្សចំនួន៥នាក់បានបន្តរៀនទៅថ្នាក់រដ្ឋផងដែរ។
- មជ្ឈមណ្ឌលធំចំនួន២ត្រូវបានសាងសង់សម្រាប់ក្មេងៗចូលអានសៀវភៅនិងរៀនកំព្យូទ័រ។ ដោយមានមណ្ឌលចល័តចំនួន២ផ្សេងទៀតត្រូវបានសាងសង់ ផងដែរសម្រាប់ក្មេងៗនៅតាមចម្ការស្រែបានទទួលការរៀនសូត្រផងដែរ។
- អក្ខរក្រមភាសាកាវែតចំនួន៥ ត្រូវបានកែសម្រួលនិងទទួលបានការយល់ព្រមដាក់អោយប្រើប្រាស់ជាផ្លូវការដោយក្រសួងអប់រំយុវជន និងកីឡា។

## II. របាយការណ៍សង្ខេបហិរញ្ញវត្ថុ

### របាយការណ៍ប្រាក់ចំណូល

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| ប្រាក់ដែលទទួលបានពីម្ចាស់ជំនួយនិងផ្សេងៗ | 2020 | 2019 |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ICCO & Kerk in Actie ("ICCO") | 88,172 | 20,404 |
| New Life Literacy, Project Outreach and Prolieracy ("NLL") | 22,650 | 49,134 |
| DVV International (through Welthungerhlife) ("DVV") | 19,539 | 9,556 |
| Norwegian People's Aid Cambodia (˝NPA˝) | 48,639 | 41,998 |
| Plan Cambodia -SIDA | 187 | 32,508 |
| Sternsinger International | 13,727 | 24,067 |
| Mission Alliance ("MA") | 140,193 | 99,961 |
| Child Right Coalition Cambodia ("CRC-Oxfarm") | 29,556 | 45,632 |
| Child's Dream ("CD") | 51,483 | - |
| Development and Partnership in Action ("DPA-Cord") | 20,250 | - |
| Plan International New Generation | 97,250 | 53,556 |

| | | |
|---|---|---|
| SNV Netherlands Development Organisation ("SNV") | - | 15,212 |
| Secours Catholique/Caritas France ("SCCF") | - | 4,347 |
| Foundation Ensemble ("FE") | - | 11,821 |
| Other income | 9,783 | 19,998 |
| **សរុបចំណូល** | **541,429** | **428,194** |




## របាយការណ៍ប្រាក់ចំណាយ

សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| ចំណាយលើគម្រោងប្រតិបត្តិការ | 2020 | 2019 |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ICCO & Kerk in Actie ("ICCO") | 54,222 | 148,956 |
| New Life Literacy, Project Outreach and Prolieracy ("NLL") | 17,241 | 43,201 |
| DVV International (through Welthungerhlife) ("DVV") | 19,866 | 9,252 |
| Norwegian People's Aid Cambodia (˝NPA˝) | 48,885 | 41,313 |
| Plan Cambodia -SIDA | | 35,982 |
| Sternsinger International | 13,803 | 21,858 |

| | | |
|---|---|---|
| Mission Alliance ("MA") | 147,529 | 91,190 |
| Child Right Coalition Cambodia ("CRC-Oxfarm") | 43,001 | 33,476 |
| Child's Dream ("CD") | 49,121 | |
| Development and Partnership in Action ("DPA-Cord") | 14,025 | |
| Plan International New Generation | 112,271 | 33,641 |
| SNV Netherlands Development Organisation ("SNV") | | 15,458 |
| Secours Catholique/Caritas France ("SCCF") | | |
| Foundation Ensemble ("FE") | | 20,667 |
| Critical Eco System Partnership Fund | | 7,550 |
| Other expenditure | 7,442 | 23,709 |
| **សរុបចំណាយ** | **527,405** | **526,253** |



## IV.សមាជិកក្រុមប្រឹក្សាភិបាលរបស់អង្គការNTFP

ក្នុងការលើកកំពស់ទៅលើអភិបាលកិច្ចល្អ និងការធ្វើអោយប្រសើរឡើងទៅលើការគ្រប់គ្រងនិងការចាត់ចែង នៅបច្ចុប្បន្ននេះ អង្គការអនុផលព្រៃឈើមានសមាជិកក្រុមប្រឹក្សាភិបាលចំនួន៥រូប:

- លោក ហួន ជុនឌី ប្រធានក្រុមប្រឹក្សាភិបាល
- លោក John Ashish សមាជិកក្រុមប្រឹក្សាភិបាល
- លោក រត្ន៍ រម្យនា សមាជិកក្រុមប្រឹក្សាភិបាល
- លោកស្រី លៀង អ៊ី សមាជិកក្រុមប្រឹក្សាភិបាល
- លោក ភុំ ចុល សមាជិកក្រុមប្រឹក្សាភិបាល

រតនគិរី,ថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០២១

រៀបចំដោយ

នាយកអង្គការអនុផលព្រៃឈើ(NTFP)

លោកឡុងសេរី